

# ពិធីសារណាហ្គូយ៉ា

ស្តីពី

# សិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែក ផលប្រយោជន៍ពីការប្រើប្រាស់ ធនធានសេនេទិកដោយស្មើភាព និងសមធម៌

នៃ

# អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ

អត្ថបទ និងឧបសម្ព័ន្ធ

# ពិធីសារណាហ្គូយ៉ា
## ស្តីពី
# សិទ្ធិទទួលផលពីធនធានសេនេទិក និងបែងចែក ផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក ដោយស្មើភាព និងសមធម៌
## នៃ
# អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ

អត្ថបទ និងឧបសម្ព័ន្ធ

លេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
ទីក្រុងម៉ុងរ៉េអាល

អ នុ ស ញ្ញា ស ហ ប្រ ជា ជា តិ ស្តី ពី ជី វៈ ច ម្រុះ
អង្គការសហប្រជាជាតិ

លេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ
៤១៣ ផ្លូវ St. Jacques Street West អាគារ ៨០០
ទីក្រុងម៉ុងរ៉េអាល ខេត្តហ្គីបិក ប្រទេសកាណាដា H2Y 1N9
ទូរស័ព្ទ ៖ +១ (៥១៤) ២៨៨ ២២២០
ទូរសារ ៖ +១ (៥១៤) ២៨៨ ៦៥៨៨
សារអេឡិចត្រូនិក ៖ secretariat@cbd.int
គេហទំព័រ ៖ www.cbd.int

រក្សាសិទ្ធិ © ២០១១ ដោយលេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពផ្សាយនៅឆ្នាំ២០១១
បោះពុម្ពនៅក្នុងប្រទេសកាណាដា

ISBN: 92-9225-306-9

ឯកសារនេះអាចបោះពុម្ពឡើងសម្រាប់គោលបំណងអប់រំ ឬមិនស្វែងរកប្រាក់កម្រៃដោយមិនចាំបាច់ស្នើសុំការអនុញ្ញាតពិសេសពីម្ចាស់រក្សាសិទ្ធិឡើយ ដោយគ្រាន់តែបញ្ជាក់ទទួលស្គាល់ពីប្រភពនៃឯកសារនេះ។ លេខាធិការដ្ឋានអនុសញ្ញាសូមស្វាគមន៍ដល់ការបញ្ជូនមកខ្លួននូវឯកសារថតចម្លងនៃការបោះពុម្ពផ្សាយទាំងឡាយណាដែលប្រើប្រាស់ឯកសារនេះជាប្រភពព័ត៌មាន។

កំណត់ត្រាចុះបញ្ជីនៅលេខាធិការដ្ឋាន ៖

ពិធីសារណាហ្គូយ៉ាស្តីពីពិធីសារណាហ្គូយ៉ាស្តីពីសិទ្ធិទទួលផលពីធនជាសេនេទិក និងបែងការចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាពគ្នា និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ៖ អត្ថបទ និងឧបសម្ព័ន្ធ /លេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ។
សេចក្តីសង្ខេប ៖ "ឯកសារនេះមានអត្ថបទ និងឧបសម្ព័ន្ធនៃពីធីសារណាហ្គូយ៉ាស្តីពីសិទ្ធិទទួលផលពីធនជាសេនេទិក និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាពគ្នា និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ" ដែលជាការសម្គាល់របស់អ្នកបោះពុម្ព។

ISBN 92-9225-306-9

១. ការអភិរក្សជីវៈចម្រុះ - ច្បាប់ និងបទប្បញ្ញត្តិ ២. ការអភិរក្សធនធានសេនេទិក - ច្បាប់ និងបទប្បញ្ញត្តិ ៣. ជីវៈចម្រុះ - កិច្ចសហប្រតិបត្តិការអន្តរជាតិ ៤. កិច្ចការអភិរក្សជីវៈចម្រុះ
I. អនុសញ្ញាស្តីពីជីវៈចម្រុះ (១៩៩២)។ ពិធីសារ ។ល។ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ II. សន្និសីទភាគីអនុសញ្ញាស្តីពីជីវៈចម្រុះ (ឆ្នាំ២០១០ ៖ ណាហ្គូយ៉ា ប្រទេសជប៉ុន) III. អង្គការសហប្រជាជាតិ K3488 .A48 2011

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខាធិការដ្ឋានអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ

# សេចក្តីផ្តើម

អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ត្រូវបានដាក់ឱ្យចុះហត្ថលេខា នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩២ នៅសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ (សន្និសីទកំពូលនៅទីក្រុងរីយ៉ូស្តីពីផែនដី) និងចូលជាធរមាននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣។ អនុសញ្ញានេះគឺជាឯកសារអន្តរជាតិតែមួយគត់ដែលឆ្លុះបញ្ចាំងជីវៈចម្រុះយ៉ាងទូលំទូលាយ។ អនុសញ្ញានេះមានគោលបំណង៣ គឺការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានរបស់ជីវៈចម្រុះប្រកបដោយនិរន្តរភាព និងបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌។

ដើម្បីអនុវត្តគោលបំណងទី៣ ឱ្យបានប្រសើរ មហាសន្និបាតស្តីពីការអភិវឌ្ឍដោយនិរន្តរភាព(នៅទីក្រុង Johannesburg នាខែកញ្ញា ឆ្នាំ២០០២) បានអំពាវនាវឱ្យមានការចរចានូវរបបអន្តរជាតិមួយ នៅក្នុងក្របខ័ណ្ឌ នៃអនុសញ្ញានេះដើម្បីជម្រុញ និងការពារបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក ដោយស្មើភាព និងសមធម៌។ សន្និសីទភាគីជាសមាជិកនៃអនុសញ្ញានេះបានឆ្លើយតបនៅឯកិច្ចប្រជុំលើកទី៧ របស់ខ្លួនក្នុងឆ្នាំ ២០០៤ ដោយធ្វើការកំណត់អាណត្តិក្រុមការងារចំពោះកិច្ចរបស់ខ្លួនស្តីពីការទទួល និងការចែករំលែក សម្រាប់បកស្រាយ និងចរចាបង្កើតរបបអន្តរជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ធនធានសេនេទិកដើម្បីប្រើប្រាស់ធនធានសេនេទិក និងបែងចែកផលប្រយោជន៍ ក្នុងគោលបំណងអនុវត្តឱ្យមានប្រសិទ្ធភាពនូវមាត្រា១៥ (ការទទួលធនធានសេនេទិក) និងមាត្រា៨(ញ) (ចំណេះដឹងជាប្រពៃណី) នៃអនុសញ្ញានេះ និងជាគោលបំណងទាំង ឬទី៣ របស់អនុសញ្ញា។

បន្ទាប់ពីការចរចាអស់រយៈពេលប្រាំមួយឆ្នាំរួចមក ពិធីសារណាហ្គូយ៉ាស្តីពីការទទួល និងបែងចែកដោយស្មើភាព និងសមធម៌ នូវផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ត្រូវបានអនុម័តនៅឯកិច្ចប្រជុំលើកទី១០ នៃសន្និសីទភាគីជាសមាជិក នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០១០ ក្នុងទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុន ។

ពិធីសារនេះធ្វើឱ្យគោលបំណងទី៣ នៃអនុសញ្ញាសហប្រជាជាតិស្តីពី ជីវៈចម្រុះមានការរីកចម្រើនគួរឱ្យកត់សំគាល់ ដោយផ្តល់នូវមូលដ្ឋានរឹងមាំច្បាស់លាស់ និងមានតម្លាភាពកាន់តែប្រសើរឡើងខាងផ្នែកច្បាប់សម្រាប់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ធនធានសេនេទិក។ កាតព្វកិច្ចជាក់លាក់ដើម្បីគាំទ្រដល់ការ អនុវត្តច្បាប់ក្នុងប្រទេស ឬតាមលក្ខខណ្ឌច្បាប់នៃភាគីផ្តល់ធនធានសេនេទិក និងកាតព្វកិច្ចជាកិច្ចសន្យាដែលបានឆ្លុះបញ្ចាំងក្នុងក្របខ័ណ្ឌព្រមព្រៀងរួម គឺជាចំណុចថ្មីចាំបាច់មួយនៃពិធីសារនេះ។ បទប្បញ្ញត្តិដែលត្រូវគោរពតាមទាំងនេះ ក៏ដូចជាបទប្បញ្ញត្តិដែលកំណត់លក្ខខណ្ឌ ដែលអាចព្យាករបានប្រសើរជាងមុនក្នុងការទទួលធនធានសេនេទិក និងរួមចំណែកជានាដល់ការចែករំលែកផលប្រយោជន៍ នៅពេលធនធានសេនេទិកត្រូវបានយកចេញពីភាគីមួយ ដែលផ្តល់ធនធានសេនេទិក។ ក្រៅពីនេះបទប្បញ្ញត្តិនៃពិធីសារស្តីពីការប្រើប្រាស់ចំណេះដឹងជាប្រពៃណីរបស់សហគមន៍ជនជាតិដើម និងសហគមន៍មូលដ្ឋានពាក់ព័ន្ធនឹងធនធានសេនេទិក នឹងពង្រឹងសមត្ថភាពរបស់សហគមន៍ទាំងនេះក្នុងការទទួលផលប្រយោជន៍ពីការប្រើប្រាស់ចំណេះដឹង ការច្នៃប្រឌិតថ្មី និងការអនុវត្ត ។

ដោយមានការលើកកម្ពស់ការប្រើប្រាស់ធនធានសេនេទិក និងចំណេះដឹងពាក់ព័ន្ធជាប្រពៃណី និងដោយមានការពង្រឹងឱកាសក្នុងបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ ពីការប្រើប្រាស់ធនធានសេនេទិកនោះ ពិធីសារនេះនឹងលើកទឹកចិត្តដល់ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ដោយនិរន្តរភាពនូវសមាសភាគរបស់ជីវៈចម្រុះ និងលើកកម្ពស់ការរួមចំណែកច្រើនទៀតនៃជីវៈចម្រុះក្នុងការអភិវឌ្ឍដោយនិរន្តរភាព និងសុខុមាលភាពមនុស្ស។

# ពិធីសារណាហ្គូយ៉ា ស្ដីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ ធនធានសេនេទិកដោយស្មើភាព និងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិស្ដីពីជីវៈចម្រុះ

ភាគីនៃពិធីសារនេះ

*ជា* ភាគីនៃអនុសញ្ញាសហប្រជាជាតិស្ដីពីជីវៈចម្រុះ ដែលចាប់ពីពេលនេះតទៅ ហៅថា "អនុសញ្ញា"។

*ដោយរំលឹកឡើងវិញ* ថាបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ពីការប្រើប្រាស់ធនធានសេនេទិក គឺជាគោលបំណងមួយក្នុងចំណោមគោលបំណងស្នូលទាំង៣ នៃអនុសញ្ញានេះ និងដោយទទួលស្គាល់ថា ពិធីសារនេះបន្តអនុវត្តនូវគោលបំណងនេះនៅក្នុងអនុសញ្ញា។

*ដោយធ្វើការអះអាងជាថ្មីឡើងវិញ* នូវសិទ្ធិអធិបតេយ្យនៃរដ្ឋនានា លើធនធានធម្មជាតិរបស់ខ្លួន និងយោងទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

*ដោយរំលឹកឡើងវិញបន្ថែមទៀតលើ* មាត្រា១៥ នៃអនុសញ្ញានេះ។

*ដោយទទួលស្គាល់* ពីវិភាគទានដ៏សំខាន់ៗ ក្នុងការអភិវឌ្ឍដោយនិរន្តរភាព ដែលធ្វើឡើងដោយការផ្ទេរបច្ចេកវិទ្យា និងសហប្រតិបត្តិការក្នុងការកសាងសមត្ថភាពស្រាវជ្រាវ និងការច្នៃប្រឌិតថ្មីៗ ដើម្បីបន្ថែមតម្លៃដល់ធនធានសេនេទិកនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ យោងតាមមាត្រា១៦ និង១៩ នៃអនុសញ្ញានេះ។

*ដោយទទួលស្គាល់ថា* ការយល់ដឹងរបស់សាធារណជនអំពីតម្លៃសេដ្ឋកិច្ចនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងបែងចែកដោយស្មើភាព និងសមធម៌នូវតម្លៃសេដ្ឋកិច្ចនេះ ព្រមទាំងការអភិរក្សជីវៈចម្រុះ គឺជាការលើកទឹកចិត្តដ៏សំខាន់សម្រាប់ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃសមាសភាគរបស់វា។

*ដោយទទួលស្គាល់ពី* តួនាទីយ៉ាងមានសក្ដានុពលក្នុងការទទួល និងបែងចែកផលប្រយោជន៍ ដែលនឹងនាំដល់ការអភិរក្ស ការប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះ ការលុបបំបាត់ភាពក្រីក្រ និងនិរន្តរភាពបរិស្ថាន ជាលទ្ធផលការរួមចំណែកដល់ការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

*ដោយទទួលស្គាល់* ពីទំនាក់ទំនងរវាងការទទួលធនធានសេនេទិក និងការបែងចែកដោយស្មើភាព និងសមធម៌ នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានបែបនេះ។

*ដោយទទួលស្គាល់បន្ថែម* ពីសារៈសំខាន់ក្នុងការផ្ដល់ភាពច្បាស់លាស់ខាងផ្លូវច្បាប់ ទាក់ទងនឹងការទទួលធនធានសេនេទិក និងការបែងចែកដោយស្មើភាព និងសមធម៌ នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានទាំងនេះ។

*ដោយទទួលស្គាល់បន្ថែមទៀត* ពីសារៈសំខាន់ក្នុងការលើកកំពស់ដោយស្មើភាព និងសមធម៌ ក្នុងការចរចាលក្ខខណ្ឌព្រមព្រៀងរួមរវាងអ្នកផ្ដល់ និងអ្នកប្រើប្រាស់ធនធានសេនេទិក។

*ដោយទទួលស្គាល់ផងដែរ* ពីតួនាទីដ៏មានសារៈសំខាន់ដែលថា ស្ត្រីដើរ តួនាទីក្នុងការទទួល និងបែងចែកផលប្រយោជន៍ និងដោយបញ្ជាក់អះអាងពី សេចក្ដីត្រូវការឱ្យមានការចូលរួមពេញលេញរបស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់ក្នុងការបង្កើត និងអនុវត្តគោលនយោបាយសម្រាប់ការអភិរក្សជីវៈចម្រុះ។

*ដោយប្ដេជ្ញា* គាំទ្រថែមទៀតដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃបទប្បញ្ញត្តិក្នុងការទទួល និងបែងចែកផលប្រយោជន៍នៃអនុសញ្ញានេះ។

*ដោយទទួលស្គាល់ថា* ដំណោះស្រាយបែបច្នៃប្រឌិតថ្មីៗត្រូវការជាចាំបាច់ដើម្បីបែងចែកដោយស្មើភាព និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីទាក់ទងនឹងធនធានសេនេទិក ដែលកើតឡើងក្នុងស្ថានការណ៍ឆ្លងដែន ឬដែលពុំអាចផ្តល់ ឬទទួលបានការឯកភាពជាមុនដោយមានព័ត៌មានគ្រប់គ្រាន់។

*ដោយទទួលស្គាល់* ពីសារៈសំខាន់នៃធនធានសេនេទិកចំពោះសន្តិសុខស្បៀង សុខភាពសាធារណៈ ការអភិរក្សជីវៈចម្រុះ ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

*ដោយទទួលស្គាល់* ពីលក្ខណៈពិសេសនៃជីវៈចម្រុះសម្រាប់កសិកម្ម គុណសម្បត្តិបែបដោយឡែកពិសេសរបស់ជីវៈចម្រុះ និងបញ្ហាដែលចាំបាច់ឱ្យមានដំណោះស្រាយបែបដោយឡែកពិសេស។

*ដោយទទួលស្គាល់* ពីការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេសទាំងអស់ទាក់ទងនឹងធនធានសេនេទិកសម្រាប់ស្បៀង និងកសិកម្ម ក៏ដូចជាលក្ខណៈពិសេស និងសារៈសំខាន់នៃធនធានទាំងនេះ ដើម្បីសម្រេចឱ្យបាននូវសន្តិសុខស្បៀងលើពិភពលោក និងដើម្បីការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ក្នុងបរិបទនៃការកាត់បន្ថយភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ ដោយទទួលស្គាល់លើតួនាទីសំខាន់នៃសន្ធិសញ្ញាអន្តរជាតិ ស្តីពីធនធានសេនេទិក រុក្ខជាតិសម្រាប់ស្បៀង និងកសិកម្ម និងគណៈកម្មការ FAO ស្តីពីធនធានសេនេទិកសម្រាប់ស្បៀង និងកសិកម្ម។

*ដោយបានពិនិត្យពិចារណាលើ* និយ័តកម្មសុខភាពអន្តរជាតិ (២០០៥) នៃអង្គការសុខភាពពិភពលោក និងសារៈសំខាន់ក្នុងការធានា កុំឱ្យមានជំងឺឆ្លងមកមនុស្ស ដើម្បីត្រៀមឱ្យបានរួចរាល់សម្រាប់សុខភាពសាធារណៈ និងដើម្បីកំណត់ការឆ្លើយតប។

*ដោយទទួលស្គាល់លើ* ការងារដែលកំពុងអនុវត្តក្នុងវេទិកាអន្តរជាតិ ផ្សេងៗទៀតទាក់ទងជាមួយការទទួល និងការបែងចែកផលប្រយោជន៍។

*ដោយរំលឹកឡើងវិញលើ* ប្រព័ន្ធពហុភាគីក្នុងការទទួល និងបែងចែកផលប្រយោជន៍ ដែលបានបង្កើតឡើងក្រោមសន្ធិសញ្ញាអន្តរជាតិស្តីពីធនធានសេនេទិក រុក្ខជាតិសម្រាប់ស្បៀង និងកសិកម្មដោយអនុលោមតាមអនុសញ្ញានេះ។

*ដោយទទួលស្គាល់ថា* ឯកសារអន្តរជាតិដែលទាក់ទងជាមួយនឹងការទទួល និងបែងចែកផលប្រយោជន៍គួរគាំទ្រគ្នាទៅវិញទៅមកដើម្បីឈានទៅសម្រេចគោលបំណងនៃអនុសញ្ញានេះ។

*ដោយរំលឹកឡើងវិញលើ* ទំនាក់ទំនងមាត្រា ៨ (ញ) នៃអនុសញ្ញានេះដែលទាក់ទងទៅនឹងចំណេះដឹងជាប្រពៃណីអំពីធនធានសេនេទិក និងបែងចែកដោយស្មើភាព និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ចំណេះដឹងបែបនេះ។

*ដោយកត់សំគាល់ឃើញពី* អន្តរទំនាក់ទំនងរវាងធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីដែលជាសភាពពុំអាចបំបែកចេញពីគ្នានៃសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន សារៈសំខាន់នៃចំណេះដឹងជាប្រពៃណីសម្រាប់ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាគធនធាន ព្រមទាំងសម្រាប់ជីវភាពរស់នៅដោយចីរភាពនៃសហគមន៍ទាំងនេះ។

*ដោយទទួលស្គាល់ពី*ស្ថានការណ៍នានាដែលថាចំណេះដឹងជាប្រពៃណីដែលទាក់ទងនឹងធនធានសេនេទិកមានអាទិភាពនៅក្នុង ឬគ្រប់គ្រងដោយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

*ដោយយល់ដឹងដល់ថា* វាជាសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងការកំណត់ម្ចាស់ត្រឹមត្រូវ នៃចំណេះដឹងជាប្រពៃណីពាក់ព័ន្ធជាមួយធនធានសេនេទិកនៅក្នុងសហគមន៍របស់ខ្លួន។

*ដោយទទួលស្គាល់បន្ថែមពី* ស្ថានការណ៍ដោយឡែកពិសេសថា ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធជាមួយធនធានសេនេទិក មានអត្ថិភាពនៅក្នុងប្រទេសជាច្រើន ជាទម្រង់និយាយពីមាត់មួយទៅមាត់មួយ ឬលាយលក្ខណ៍អក្សរ ឬទម្រង់ផ្សេងៗដែលឆ្លុះបញ្ចាំងពីមរតកវប្បធម៌ដ៏សំបូរបែបទាក់ទងទៅនឹងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវៈចម្រុះ។

*ដោយកត់សម្គាល់ពី* សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិរបស់ជនជាតិដើមភាគតិច និង

*ដោយមានការបញ្ជាក់ថា* ពុំមានអ្វីក្នុងពិធីសារនេះ ត្រូវបានយកមកបកស្រាយជាការកាត់បន្ថយ ឬលុបចោលសិទ្ធិដែលមានស្រាប់របស់សហគមន៍ជនជាតិដើម និងមូលដ្ឋានឡើយនោះ

បានព្រមព្រៀងដូចតទៅនេះ ៖

## មាត្រា ១
## គោលបំណង

គោលបំណងនៃពិធីសារនេះគឺការបែងចែកដោយស្មើភាព និងសមធម៌ នូវផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក រួមទាំងការទទួលធនធានសេនេទិក និងការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធឱ្យបានសមស្រប ដោយយកចិត្តទុកដាក់លើសិទ្ធិទាំងអស់នៃធនធាន និងបច្ចេកវិទ្យាទាំងនោះ និងការផ្តល់ហិរញ្ញប្បទានសមស្របដែលជាហេតុនាំដល់ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់សមាសភាគរបស់វាដោយនិរន្តរភាព។

## មាត្រា ២
## ការប្រើប្រាស់បច្ចេកស័ព្ទ

បច្ចេកស័ព្ទដែលបានកំណត់ក្នុងមាត្រា២ នៃអនុសញ្ញា ត្រូវអនុវត្តចំពោះពិធីសារនេះ។ ពិធីសារនេះមានបច្ចេកស័ព្ទដូចខាងក្រោម៖

(ក) "សន្និសីទភាគី" មានន័យថាសន្និសីទភាគីទាំងអស់នៃអនុសញ្ញានេះ។

(ខ) "អនុសញ្ញា" មានន័យថាអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ។

(គ) "ការប្រើប្រាស់ធនធានសេនេទិក" មានន័យថា ការធ្វើការស្រាវជ្រាវ និងអភិវឌ្ឍធនធានសេនេទិក និង/ឬសមាសភាពជីវគីមីនៃធនធានសេនេទិក ដោយរួមទាំងតាមរយៈការអនុវត្តជីវបច្ចេកវិទ្យា ដូចមានចែងក្នុងមាត្រា២ នៃអនុសញ្ញា។

(ឃ) "ជីវបច្ចេកវិទ្យា" ដូចមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះមានន័យថា ការអនុវត្តជីវបច្ចេកវិទ្យាណាមួយដែលប្រើប្រាស់ប្រព័ន្ធជីវសាស្ត្រ សារពាង្គកាយរស់ ឬសារពាង្គកាយបំប្លែង ដើម្បីបង្កើត ឬកែប្រែផលិតផល ឬការកែច្នៃសម្រាប់ការប្រើប្រាស់ជាក់លាក់។

(ង) "សារពាង្គកាយបំប្លែង" សំដៅដល់សមាសភាពជីវគីមីដែលបានកើតឡើងដោយធម្មជាតិបណ្តាលមកពីការបញ្ចេញ ឬដំណើរការបំប្លែសេនេទិកនៃធនធានជីវសាស្ត្រ ឬធនធានសេនេទិក បើទោះបីជាសមាសភាពនេះពុំមានឯកតាតំណសមាសភាពសកម្មក៏ដោយ។

## មាត្រា ៣
## វិសាលភាព

ពិធីសារនេះត្រូវអនុវត្តចំពោះធនធានសេនេទិក នៅក្នុងវិសាលភាពនៃមាត្រា១៥ របស់អនុសញ្ញា និងអនុវត្តចំពោះផលប្រយោជន៍ពីការប្រើប្រាស់ធនធានទាំងនេះ។ ពិធីសារនេះក៏ត្រូវអនុវត្តផងដែរចំពោះចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិកដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញា ព្រមទាំងចំពោះផលប្រយោជន៍ពីការប្រើប្រាស់ចំណេះដឹង។

## មាត្រា ៤
## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀង និងឯកសារច្បាប់អន្តរជាតិ

១. បទប្បញ្ញត្តិនៃពិធីសារនេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយដែលទទួលបានពីកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន លើកលែងតែក្នុងករណីនៃការប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចទាំងនោះបង្កភាពមហន្តរាយធ្ងន់ធ្ងរ ឬការគំរាមកំហែងដល់ជីវៈចម្រុះ។ កថាខ័ណ្ឌនេះពុំមានគោលបំណងបង្កើតឱ្យមានឋានានុក្រមរវាងពិធីសារនេះ និងឯកសារច្បាប់អន្តរជាតិដទៃទៀតនោះទេ។

២. ពុំមានអ្វីនៅក្នុងពិធីសារនេះត្រូវរារាំងភាគីមិនឱ្យអភិវឌ្ឍ និងអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធដទៃទៀតនោះទេ ដោយរួមទាំងការទទួល និងកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍ជាក់លាក់ ប្រសិនបើការទទួល និងកិច្ចព្រមព្រៀងទាំងនេះមិនជំទាស់ទៅនឹងគោលបំណងនៃអនុសញ្ញា និងពិធីសារនេះ។

៣. ពិធីសារនេះត្រូវអនុវត្ត ក្នុងលក្ខណៈគាំទ្ររួមគ្នាជាមួយឯកសារច្បាប់អន្តរជាតិដទៃដែលមានទំនាក់ទំនងជាមួយពិធីសារនេះ។ ការយកចិត្តទុកដាក់សមស្របគួរធ្វើឡើងចំពោះការងារ ឬការអនុវត្តដែលមានប្រយោជន៍ និងពាក់ព័ន្ធដែលកំពុងដំណើរការអនុលោមតាមឯកសារច្បាប់អន្តរជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា ប្រសិនបើឯកសារ និងអង្គការទាំងនោះមិនជំទាស់ទៅនឹងគោលបំណងនៃអនុសញ្ញា និងពិធីសារនេះ។

៤. ពិធីសារនេះជាឯកសារច្បាប់មួយសម្រាប់អនុវត្តបទប្បញ្ញត្តិនានានៃអនុសញ្ញាស្តីពីការទទួល និងការបែងចែកផលប្រយោជន៍។ ក្នុងករណីដែលឯកសារច្បាប់អន្តរជាតិស្តីពីការទទួល និងបែងចែកផលប្រយោជន៍ត្រូវអនុវត្តដែលស៊ីគ្នា និងមិនជំទាស់ទៅនឹងគោលបំណងនៃអនុសញ្ញា និងពិធីសារទេ ពិធីសារនេះមិនបង្គាប់ភាគីណាមួយ ឬច្រើនឱ្យអនុវត្តតាមឯកសារច្បាប់ពិសេសចំពោះធនធានសេនេទិក ដែលមានកំណត់ និងជាគោលបំណងនៃឯកសារច្បាប់ពិសេសនោះ។

## មាត្រា ៥
## ការបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌

១. អនុលោមតាមមាត្រា១៥ កថាខ័ណ្ឌ៣ និង៧ នៃអនុសញ្ញានេះ ផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក ក៏ដូចជាដំណើរការ និងការធ្វើពាណិជ្ជកម្មជាបន្តបន្ទាប់ត្រូវបែងចែកឱ្យបានស្មើភាព និងសមធម៌ ជាមួយ

ភាគីដែលផ្តល់ធនធានសេនេទិកនេះ មានន័យថាជាប្រទេសនៃប្រភពធនធាន ឬភាគីមួយដែលត្រូវការធនធានសេនេទិក ស្របតាមអនុសញ្ញានេះ។ បែងចែកបែបនេះត្រូវពឹងផ្អែកលើលក្ខខណ្ឌព្រមព្រៀងរួម ។

២. ភាគីនីមួយៗត្រូវមានវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយដែលសមស្របក្នុងបំណងធានាថាផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិកដែលត្រូវបានដំណើរការដោយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ក្នុងប្រទេស ទាក់ទងទៅនឹងសិទ្ធិដែលត្រូវបានបង្កើតឡើងសម្រាប់សហគមន៍ជនជាតិដើម និងសហគមន៍មូលដ្ឋានលើធនធានសេនេទិកទាំងនេះ ត្រូវចែករំលែកស្មើភាព និងសមធម៌ជាមួយសហគមន៍ពាក់ព័ន្ធ ដោយផ្អែកលើលក្ខខណ្ឌព្រមព្រៀងរួម។

៣. ដើម្បីអនុវត្តកថាខ័ណ្ឌ១ ខាងលើ ភាគីនីមួយៗត្រូវមានវិធានការច្បាប់រដ្ឋបាល ឬគោលនយោបាយសមស្រប។
៤. ផលប្រយោជន៍អាចរាប់បញ្ចូលទាំងផលប្រយោជន៍ជាសាច់ប្រាក់ និងមិនមែនជាសាច់ប្រាក់ រួមទាំង ប៉ុន្តែមិនត្រូវកំណត់ត្រឹមតែផលប្រយោជន៍ដែលមានកំណត់នៅក្នុងបញ្ជីក្នុងឧបសម្ព័ន្ធនោះទេ។

៥. ភាគីនីមួយៗត្រូវមានវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយសមស្រប ដើម្បីធានាថាផលប្រយោជន៍ពីការប្រើប្រាស់ចំណេះដឹងបែបប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក ត្រូវបែងចែកឱ្យស្មើភាព និងសមធម៌ ជាមួយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលមានចំណេះដឹងទាំងនេះ។ ការបែងចែកបែបនេះត្រូវផ្អែកលើលក្ខខណ្ឌព្រមព្រៀងរួម ។

## មាត្រា ៦
## ការទទួលធនធានសេនេទិក

១. នៅក្នុងកាអនុវត្តសិទ្ធិអធិបតេយ្យលើធនធានធម្មជាតិ និងយោងតាមបទប្បញ្ញត្តិក្នុងប្រទេសស្តីពីការទទួល និងបែងចែកផលប្រយោជន៍ ឬលក្ខខណ្ឌផ្លូវច្បាប់ផ្សេងៗទៀត ការទទួលធនធានសេនេទិកសម្រាប់យកមកប្រើប្រាស់ ត្រូវពឹងផ្អែកលើការព្រមព្រៀង ដោយផ្អែកលើមានព័ត៌មានគ្រប់គ្រាន់ជាមុនជាមួយភាគីដែលផ្តត់ផ្គង់ធនធានទាំងនោះ មានន័យថាជាប្រទេសនៃប្រភពដើមធនធាន ឬភាគីមួយដែលត្រូវការធនធានសេនេទិក ដោយអនុលោមតាមអនុសញ្ញានេះ លើកលែងតែមានកំណត់ដោយឡែករបស់ភាគីនោះ។

២. អនុលោមតាមច្បាប់ក្នុងប្រទេស ភាគីនីមួយៗត្រូវមានវិធានការសមស្រប ដើម្បីធានាថា ការព្រមព្រៀង ឬការឯកភាពដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ និងការពាក់ព័ន្ធរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ត្រូវបានធ្វើឡើងមុននឹងទទួលធនធានសេនេទិកដែលពួកគេមានសិទ្ធិដែលត្រូវបានបង្កើតឡើងដើម្បីទទួលធនធានទាំងនេះ។

៣. យោងតាមកថាខ័ណ្ឌ១ ខាងលើ ភាគីដែលត្រូវការឱ្យមានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន ត្រូវមានវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយសំខាន់ៗសមស្របដើម្បី ៖

(ក) ភាពប្រាកដប្រជា ភាពច្បាស់លាស់ និងតម្លាភាពនៃបទប្បញ្ញត្តិ ឬ លក្ខខណ្ឌច្បាប់ផ្សេងៗទៀត ស្តីពីការទទួល និងបែងចែកផលប្រយោជន៍នៅក្នុងប្រទេស

(ខ) មានវិធាន និងនីតិវិធីដែលស្មើភាព និងមិនតាមអំពើចិត្តស្តីពីការទទួលធនធានសេនេទិក
(គ) មានព័ត៌មានអំពីវិធីអនុវត្តសម្រាប់ការព្រមព្រៀងជាមុនដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់
(ឃ) មានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលច្បាស់លាស់ និងមានតម្លាភាព ពីអាជ្ញាធរជាតិមានសមត្ថកិច្ច ដោយធានាពីតម្លៃ និងរយៈពេលសមស្រប
(ង) នៅពេលទទួលបាន ធ្វើការចេញលិខិតអនុញ្ញាត ឬលិខិតដែលមានតម្លៃស្មើ ជាភស្តុតាងនៃសេចក្តីសម្រេចក្នុងការទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងជាភស្តុតាងនៃការបង្កើតលក្ខខណ្ឌព្រមព្រៀងរួម ព្រមទាំងជូនព័ត៌មានទៅការិយាល័យចែកចាយព័ត៌មាន ស្តីពីការទទួល និងបែងចែកផលប្រយោជន៍
(ច) ក្នុងករណីដែលអាចអនុវត្តបាន និងយោងតាមច្បាប់ក្នុងប្រទេស កំណត់លក្ខណៈវិនិច្ឆ័យ និង/ឬដំណើរការដើម្បីស្វែងរកការព្រមព្រៀងដោយផ្អែកលើមានព័ត៌មានគ្រប់គ្រាន់ជាមុន ឬការឯកភាព និងការពាក់ព័ន្ធរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ក្នុងការទទួលធនធានសេនេទិក និង
(ឆ) បង្កើតវិធាន និងនីតិវិធីច្បាស់លាស់សម្រាប់ទាមទារ និងកំណត់លក្ខខណ្ឌព្រមព្រៀងរួម។ លក្ខខណ្ឌទាំងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងអាចមានប្រការផ្សេងៗដូចខាងក្រោម ៖
(i) លក្ខខណ្ឌដោះស្រាយវិវាទ
(ii) លក្ខខណ្ឌអំពីបែងចែកផលប្រយោជន៍ រួមទាំងលក្ខខណ្ឌដែលទាក់ទងទៅនឹងសិទ្ធិនៃកម្មសិទ្ធិបញ្ញា
(iii) លក្ខខណ្ឌអំពីការប្រើប្រាស់ភាគីទី៣ បើមាន និង
(iv) លក្ខខណ្ឌអំពីការផ្លាស់ប្តូរគោលបំណង ក្នុងករណីដែលអាចអនុវត្តបាន

## មាត្រា ៧
## ការទទួលចំណេះដឹងជាប្រពៃណីទាក់ទងនឹងធនធានសេនេទិក

យោងតាមច្បាប់ក្នុងប្រទេសខ្លួន ភាគីនីមួយៗត្រូវមានវិធានការសមស្របដើម្បីធានាថា ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិករបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ត្រូវស្វែងយល់ មុននឹងមានការព្រមព្រៀង ឬការឯកភាពដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ និងមានការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងធានាថាលក្ខខណ្ឌព្រមព្រៀងរួមត្រូវបានបង្កើតឡើង។

## មាត្រា ៨
## ការពិចារណាពិសេស

ក្នុងការបង្កើត និងអនុវត្តបទប្បញ្ញត្តិ ឬលក្ខខណ្ឌច្បាប់នានាស្តីពីការទទួល និងចែករំលែកផលប្រយោជន៍នោះ ភាគីនីមួយៗត្រូវ ៖
(ក) បង្កើតលក្ខខណ្ឌជម្រុញ និងលើកទឹកចិត្តដល់ការស្រាវជ្រាវដែលរួមចំណែកដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងវិធានការងាយៗ អំពីការប្រើប្រាស់ធនធានសម្រាប់គោលបំណងស្រាវជ្រាវមិនមែនពាណិជ្ជកម្ម ដោយយកចិត្តទុកដាក់លើតម្រូវការក្នុងការបង្ហាញពីការផ្លាស់ប្តូរគោលបំណងសម្រាប់ការស្រាវជ្រាវទាំងនោះ

(ខ) យកចិត្តទុកដាក់ខ្ពស់ចំពោះករណីនៃភាពបន្ទាន់ក្នុងពេលបច្ចុប្បន្ន ឬជិតមកដល់ ដែលគំរាមកំហែង ឬបំផ្លាញសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ដូចមានកំណត់នៅថ្នាក់ជាតិ ឬអន្តរជាតិ។ ភាគីអាច ពិចារណាពីតម្រូវការឱ្យមានការទទួលធនធានសេនេទិកបានឆាប់រហ័ស និងការចែករំលែកផល ប្រយោជន៍ដោយស្មើភាព និងសមធម៌បានឆាប់រហ័សពីការប្រើប្រាស់ធនធានសេនេទិកទាំងនេះ រួម ទាំងការធ្វើប្រព្រឹត្តកម្មក្នុងតម្លៃសមស្របសម្រាប់ប្រទេសនានាដែលត្រូវការចាំបាច់ ពិសេសក្នុង ប្រទេសកំពុងអភិវឌ្ឍន៍

(គ) ពិចារណាពីសារៈសំខាន់នៃធនធានសេនេទិកសម្រាប់ស្បៀង និងកសិកម្ម និងតួនាទីពិសេសរបស់ ធនធានសេនេទិកទាំងនេះសម្រាប់សន្តិសុខស្បៀង។

## មាត្រា ៩
## ការរួមចំណែកដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព

ភាគីត្រូវគាំទ្រអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ក្នុងការទទួលបាននូវផលប្រយោជន៍ផ្ទាល់ពីការប្រើប្រាស់ធនធាន សេនេទិកសំដៅដល់ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធាននៃជីវៈចម្រុះដោយនិរន្តរភាព។

## មាត្រា ១០
## យន្តបែងចែកផលប្រយោជន៍ពហុភាគីសាកល

ភាគីទាំងអស់ត្រូវពិចារណាពីតម្រូវការ និងទម្រង់បែបបទនៃយន្តការបែងចែកផលប្រយោជន៍ពហុភាគី សកល ដើម្បីបញ្ជាក់ពីការបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ ពីការប្រើប្រាស់ធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីទាក់ទងនឹងធនធានសេនេទិក ដែលមាននៅក្នុងស្ថានការណ៍ឆ្លងដែន ឬធនធានដែល អាចនឹងមិនផ្តល់ ឬទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន។ ផលប្រយោជន៍ដែលត្រូវចែក រំលែកដោយអ្នកប្រើប្រាស់ ធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីទាក់ទងនឹងធនធានសេនេទិក តាមរយៈ យន្តការនេះ ត្រូវយកមកប្រើប្រាស់ដើម្បីគាំទ្រដល់ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់សមាសភាគរបស់ ជីវៈចម្រុះ ប្រកបដោយនិរន្តរភាពក្នុងពិភពលោក។

## មាត្រា ១១
## កិច្ចសហប្រតិបត្តិការឆ្លងដែន

១. ក្នុងករណីដែលធនធានសេនេទិកដូចគ្នា ត្រូវបានរកឃើញនៅក្នុងទឹកដីនៃភាគីចុះកិច្ចសន្យាចាប់ពី២ ឡើងទៅ ភាគីទាំងនោះត្រូវព្យាយាមធ្វើសហប្រតិបត្តិការសមស្រប ដោយមានការចូលរួមពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ ក្នុងករណីដែលអាចអនុវត្តបាន ដើម្បីអនុវត្តពិធីសារនេះ។

២. ក្នុងករណីដែលចំណេះដឹងប្រពៃណីដូចគ្នាពាក់ព័ន្ធនឹងធនធានសេនេទិក ត្រូវបានចែករំលែកក្នុងចំណោម សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានមួយ ឬច្រើននៅក្នុងភាគីផ្សេងៗភាគីទាំងនោះត្រូវ ព្យាយាមធ្វើសហប្រតិបត្តិការសមស្រប ដោយមានការចូលរួមពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ មូលដ្ឋានពាក់ព័ន្ធក្នុងករណីដែលអាចអនុវត្តបាន ដើម្បីអនុវត្តពិធីសារនេះ។

## មាត្រា ១២
## ចំណេះដឹងប្រពៃណីទាក់ទងនឹងធនធានសេនេទិក

១. ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមពិធីសារនេះ និងអនុលោមតាមច្បាប់ក្នុងប្រទេស ភាគីទាំងអស់ត្រូវគិតត្រូវពិចារណាលើច្បាប់ទំនៀមទម្លាប់របស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ពិធីសារ និងនីតិវិធីសហគមន៍ នៅពេលអនុវត្តបានអំពីចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក។

២. ដោយមានការចូលរួមយ៉ាងមានប្រសិទ្ធភាព ពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ភាគីទាំងអស់ត្រូវបង្កើតយន្តការ ដើម្បីផ្ដល់ព័ត៌មានដល់អ្នកប្រើប្រាស់សំខាន់ៗ ដែលមានចំណេះដឹងបែបប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក អំពីកាតព្វកិច្ចរបស់ខ្លួន រួមទាំងវិធានការដែលអាចប្រើបាន តាមរយៈការិយាល័យចែកចាយព័ត៌មាន ស្ដីពីការទទួល និងបែងចែកផលប្រយោជន៍សម្រាប់ទទួល និងការបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ ពីការប្រើប្រាស់ចំណេះដឹងទាំងនេះ។

៣. ភាគីទាំងអស់ ត្រូវព្យាយាមគាំទ្រឱ្យបានសមស្របដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន រួមទាំងស្ត្រីនៅក្នុងសហគមន៍ទាំងនេះក្នុងការបង្កើតនូវ ៖

(ក) ពិធីសារសហគមន៍ទាក់ទងទៅនឹងការទទួលចំណេះដឹងប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក ការបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ពីការប្រើប្រាស់ចំណេះដឹងទាំងនេះ

(ខ) តម្រូវការអប្បបរមាសម្រាប់លក្ខខណ្ឌព្រមព្រៀងរួម ដើម្បីធានាឱ្យមានការបែងចែកផលប្រយោជន៍ដោយស្មើភាព និងសមធម៌ពីការប្រើប្រាស់ចំណេះដឹងបែបប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក និង

(គ) ខសន្យាគំរូសម្រាប់ការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក។

៤. នៅក្នុងការអនុវត្តពិធីសារនេះ និងក្នុងពេលដែលអាចធ្វើបាន ភាគីទាំងអស់មិនត្រូវរឹតត្បិតលើការប្រើប្រាស់ជាទំនៀមទម្លាប់ ការផ្លាស់ប្ដូរធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ នៅក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមគោលបំណងនៃអនុសញ្ញានេះ។

## មាត្រា ១៣
## ស្ថាប័នបង្គោលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចជាតិ

១. ភាគីនីមួយៗត្រូវចាត់តាំងស្ថាប័នបង្គោលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចជាតិស្ដីពីការទទួល និងការចែករំលែកផលប្រយោជន៍ ។ ស្ថាប័នបង្គោលជាតិត្រូវរៀបចំឱ្យមានព័ត៌មានដូចខាងក្រោម ៖

(ក) សម្រាប់អ្នកដាក់ពាក្យស្នើសុំទទួលយកទៅប្រើប្រាស់ធនធានសេនេទិក និងព័ត៌មាន ស្ដីពីនីតិវិធីដើម្បីទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងបង្កើតលក្ខខណ្ឌព្រមព្រៀងរួម ក្នុងនោះរួមទាំងការបែងចែកផលប្រយោជន៍

(ខ) សម្រាប់អ្នកដាក់ពាក្យសុំទទួលយកទៅប្រើប្រាស់ នៃចំណេះដឹងប្រពៃណី ពាក់ព័ន្ធនឹងធនធានសេនេទិក ក្នុងករណីដែលមានព័ត៌មានស្ដីពីនីតិវិធី ដើម្បីទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន ឬការឯកភាព និងការចូលរួមសមស្របរបស់សហគមន៍ជនជាតិដើម

ភាគតិច និងសហគមន៍មូលដ្ឋាន និងសម្រាប់បង្កើតលក្ខខណ្ឌព្រមព្រៀងរួម ក្នុងនោះរួមទាំងការបែងចែកផលប្រយោជន៍ និង

(គ) ព័ត៌មានស្តីពីអាជ្ញាធរមានសមត្ថកិច្ចជាតិ សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ។

ស្ថាប័នបង្គោលជាតិត្រូវទទួលខុសត្រូវលើទំនាក់ទំនងជាមួយលេខាធិការដ្ឋាន។

២. ភាគីនីមួយៗត្រូវរៀបចំឱ្យមានអាជ្ញាធរមានសមត្ថកិច្ចជាតិមួយ ឬច្រើន ស្តីពីការទទួល និងបែងចែកផលប្រយោជន៍ ដោយអនុលោមតាមវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយជាតិជាធរមាន អាជ្ញាធរមានសមត្ថកិច្ចជាតិត្រូវទទួលខុសត្រូវក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ ឬក្នុងករណីដែលអាចធ្វើបានបង្ហាញភស្តុតាងជាលាយលក្ខណ៍អក្សរដែលបានបំពេញតាមលក្ខខណ្ឌក្នុងការទទួល និងត្រូវទទួលខុសត្រូវក្នុងការណែនាំពីនីតិវិធី និងតម្រូវការដែលអាចអនុវត្តបានដើម្បីទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុននិងដើម្បីដាក់លក្ខខណ្ឌព្រមព្រៀងរួមចូលជាធរមាន។

៣. ភាគីមួយអាចរៀបចំឱ្យមានអង្គភាពមួយ ដើម្បីបំពេញមុខងារជាស្ថាប័នបង្គោលផង និងជាអាជ្ញាធរមានសមត្ថកិច្ចជាតិផង ។

៤. ចំពោះការយឺតយ៉ាវនៃកាលបរិច្ឆេទក្នុងការចូលជាធរមាននៃពិធីសារនេះ ភាគីនីមួយៗ ត្រូវជូនដំណឹងដល់លេខាធិការដ្ឋានអំពីព័ត៌មានទំនាក់ទំនងនៃស្ថាប័នបង្គោលជាតិរបស់ខ្លួន និងអាជ្ញាធរមានសមត្ថកិច្ចជាតិមួយ ឬច្រើន។ ក្នុងករណី ភាគីមួយចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចជាតិច្រើន ភាគីនោះត្រូវជូនដំណឹងទៅលេខាធិការដ្ឋាននូវព័ត៌មានពាក់ព័ន្ធ ស្តីពីការទទួលខុសត្រូវរបស់អាជ្ញាធរទាំងនោះ។ ក្នុងករណីអាចអនុវត្តបាន ព័ត៌មានទាំងនោះនឹងបញ្ជាក់ជាអប្បបរមា ថាតើអាជ្ញាធរមានសមត្ថកិច្ចមួយណាទទួលខុសត្រូវលើការស្វែងរកធនធានសេនេទិក។ ភាគីនីមួយៗ ត្រូវជូនព័ត៌មានទៅលេខាធិការដ្ឋានជាបន្ទាន់ពីការផ្លាស់ប្តូរណាមួយក្នុងការចាត់តាំងស្ថាប័នបង្គោលជាតិ ឬព័ត៌មានទំនាក់ទំនង ឬទំនួលខុសត្រូវនៃអាជ្ញាធរមានសមត្ថកិច្ចជាតិមួយ ឬច្រើន។

៥. លេខាធិការដ្ឋានត្រូវរៀបចំព័ត៌មានដែលទទួលបានតាមកថាខ័ណ្ឌ៤ ខាងលើសម្រាប់តម្រូវការប្រើប្រាស់តាមរយៈការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងបែងចែកផលប្រយោជន៍។

## មាត្រា ១៤
## ការិយាល័យចែកចាយព័ត៌មាន ស្តីពីការទទួល និងបែងចែកផលប្រយោជន៍ និងបែងចែកព័ត៌មាន

១. ការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃយន្តការផ្សព្វផ្សាយព័ត៌មាន ក្នុងមាត្រា១៨ កថាខ័ណ្ឌ៣ នៃអនុសញ្ញានេះ។ ការិយាល័យនេះនឹងក្លាយទៅជាមធ្យោបាយមួយសម្រាប់ចែករំលែកព័ត៌មានដែលទាក់ទងទៅនឹងការទទួល និងការបែងចែកផលប្រយោជន៍។ ជាពិសេស ការិយាល័យនេះនឹងសម្រួលដល់ការចូលមើលព័ត៌មានរបស់ភាគីនីមួយៗ ទាក់ទងនឹងការអនុវត្តពិធីសារនេះ។

២. ដើម្បីបញ្ចៀសការប៉ះពាល់ទៅនឹងកិច្ចការពារព័ត៌មានសម្ងាត់ ភាគីនីមួយៗត្រូវផ្តល់មកឱ្យការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ នូវព័ត៌មានទាំងឡាយណាដែលជាតម្រូវការរបស់ពិធីសារនេះ ព្រមទាំងព័ត៌មានដែលទាមទារឱ្យផ្តល់ឱ្យស្របតាមសេចក្តីសម្រេច ដែលធ្វើឡើងដោយសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ។ ព័ត៌មានទាំងនោះត្រូវមាន ៖

(ក) វិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយស្តីពីការទទួល និងបែងចែកផលប្រយោជន៍

(ខ) ព័ត៌មានអំពីស្ថាប័នបង្គោលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចជាតិមួយ ឬច្រើន និង

(គ) លិខិតអនុញ្ញាត ឬលិខិតដែលមានតម្លៃស្មើដែលត្រូវចេញឱ្យនៅពេលទទួលជាភស្តុតាងនៃសេចក្តីសម្រេចដើម្បីទទួលបានការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងជាភស្តុតាងនៃការបង្កើតលក្ខខណ្ឌព្រមព្រៀងរួម។

៣. ព័ត៌មានបន្ថែម បើមាន និងសមស្រប អាចមានដូចជា ៖

(ក) អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ របស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងព័ត៌មានដែលសម្រេចរួច

(ខ) ខសន្យាគំរូ

(គ) វិធីសាស្ត្រ និងឧបករណ៍ដែលបានបង្កើតឡើងដើម្បីត្រួតពិនិត្យធនធានសេនេទិក និង

(ឃ) ក្រមប្រតិបត្តិ និងការប្រតិបត្តិដ៏ល្អ

៤. គំរូនៃការប្រតិបត្តិរបស់ការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងបែងចែកផលប្រយោជន៍រួមបញ្ចូលទាំងរបាយការណ៍សកម្មភាពរបស់ខ្លួន ត្រូវតែយកមកពិចារណា និងសម្រេចដោយយោងទៅលើសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ នៅក្នុងកិច្ចប្រជុំលើកទី១ ហើយត្រូវបានរក្សាទុកដើម្បីពិនិត្យឡើងវិញ។

## មាត្រា ១៥
## ការអនុវត្តបទប្បញ្ញត្តិ ឬលក្ខខណ្ឌច្បាប់ក្នុងប្រទេស ស្តីពីការទទួល និងការបែងចែកផលប្រយោជន៍

១. ភាគីនីមួយៗត្រូវមានវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយពាក់ព័ន្ធ សមស្រប និងមានប្រសិទ្ធភាព ដើម្បីកំណត់ថា ធនធានសេនេទិក ដែលត្រូវប្រើប្រាស់ក្នុងដែនអំណាចរបស់ពួកគេ ត្រូវបានប្រើប្រាស់ដោយអនុលោមតាមការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងដើម្បីកំណត់ថា លក្ខខណ្ឌព្រមព្រៀងរួមត្រូវបានបង្កើតឡើង ដែលតម្រូវដោយច្បាប់ ឬលក្ខខណ្ឌច្បាប់របស់ភាគីម្ខាងទៀត ស្តីពីការទទួល និងបែងចែកផលប្រយោជន៍។

២. ភាគីទាំងអស់ត្រូវមានវិធានការពាក់ព័ន្ធ សមស្រប និងមានប្រសិទ្ធភាព ដើម្បីដោះស្រាយស្ថានការណ៍មិនអនុវត្តតាមវិធានការ ដែលត្រូវបានអនុម័តតាមកថាខ័ណ្ឌ១ ខាងលើ ។

៣. នៅពេលអាចធ្វើបាន និងសមស្រប ភាគីទាំងអស់ត្រូវសហការគ្នានៅគ្រប់ករណីដែលបានចោទថាមានការបំពានដល់បទប្បញ្ញត្តិ ឬល័ក្ខខ័ណ្ឌច្បាប់ស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ក្នុងប្រទេស ដោយយោងតាមកថាខ័ណ្ឌ១ ខាងលើ។

## មាត្រា ១៦
## ការអនុវត្តតាមច្បាប់ ឬលក្ខខណ្ឌច្បាប់ក្នុងប្រទេសស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ចំពោះ ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក

១. ភាគីនីមួយៗត្រូវមានវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយពាក់ព័ន្ធ សមស្រប និងមានប្រសិទ្ធភាព ដើម្បីកំណត់ថា ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិកដែលត្រូវបានយកមកប្រើប្រាស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវបានប្រើប្រាស់ ដោយអនុលោមតាមការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន ឬការឯកភាព និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងកំណត់ថា លក្ខខណ្ឌព្រមព្រៀងរួម ត្រូវបានបង្កើតឡើង ដែលជាតម្រូវការចាំបាច់ដោយច្បាប់ ឬលក្ខខណ្ឌច្បាប់ស្តីពីការប្រើប្រាស់ និងបែងចែកផលប្រយោជន៍ក្នុងប្រទេសរបស់ភាគីដទៃទៀតដែលសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានស្ថិតនៅ។

២. ភាគីនីមួយៗត្រូវមានវិធានការពាក់ព័ន្ធ សមស្រប និងមានប្រសិទ្ធភាពដើម្បីដោះស្រាយស្ថានការណ៍ដែលមិនអនុវត្តតាមវិធានការ ដែលបានអនុម័តតាមកថាខ័ណ្ឌ១ ខាងលើ ។

៣. នៅពេលអាចធ្វើបាន និងសមស្រប ភាគីទាំងអស់ត្រូវសហការគ្នានៅគ្រប់ករណីដែលបានចោទថាមានការបំពានដល់បទប្បញ្ញត្តិ ឬលក្ខខណ្ឌច្បាប់ស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ក្នុងប្រទេស ដោយយោងតាមកថាខ័ណ្ឌ១ ខាងលើ។

## មាត្រា ១៧
## ការត្រួតពិនិត្យលើការប្រើប្រាស់ធនធានសេនេទិក

១. ដើម្បីគាំទ្រការអនុវត្ត ភាគីនីមួយៗត្រូវចាត់វិធាន សមស្របក្នុងការត្រួតពិនិត្យ និងលើកកម្ពស់តម្លាភាពអំពីការប្រើប្រាស់ធនធានសេនេទិក។ វិធានការទាំងនេះរួមមាន ៖

(ក) បង្កើតចំណុចត្រួតពិនិត្យមួយ ឬច្រើនដូចតទៅនេះ ៖

(i) នៅពេលសមស្រប ចំណុចត្រួតពិនិត្យដែលបានបង្កើតឡើងនឹងត្រូវប្រមូលព័ត៌មានពាក់ព័ន្ធដែលទាក់ទងទៅនឹងការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន រហូតដល់ប្រភពធនធានសេនេទិក ការបង្កើតលក្ខខណ្ឌព្រមព្រៀងរួម និង/ឬការប្រើប្រាស់ធនធានសេនេទិកនៅពេលសមស្រប។

(ii) នៅពេលសមស្រប និងអាស្រ័យលើលក្ខណៈពិសេសនៃចំណុចត្រួតពិនិត្យដែលត្រូវបង្កើតឡើង ភាគីនីមួយៗ តម្រូវឱ្យអ្នកប្រើប្រាស់ធនធានសេនេទិកផ្តល់ព័ត៌មានដូចដែលបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌខាងលើនៅត្រង់ចំណុចត្រួតពិនិត្យ។ ភាគីនីមួយៗ ត្រូវមានវិធានការពាក់ព័ន្ធសមស្របនិងមានប្រសិទ្ធភាព ដើម្បីបញ្ជាក់ពីការមិនអនុវត្តតាមច្បាប់ និងលក្ខខណ្ឌច្បាប់។

(iii) ដោយមិនធ្វើឱ្យប៉ះពាល់ទៅដល់កិច្ចការពារព័ត៌មានសម្ងាត់ ព័ត៌មានទាំងនេះ រួមទាំងលិខិតបញ្ជាក់ដែលទទួលស្គាល់ជាអន្តរជាតិ ប្រសិនបើមាន នឹងត្រូវបញ្ជូនទៅអាជ្ញាធរជាតិពាក់ព័ន្ធ

ទៅភាគីដែលផ្តល់ការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងទៅការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងបែងចែកផលប្រយោជន៍នៅពេលសមស្រប។

(iv) ចំណុចត្រួតពិនិត្យត្រូវតែមានប្រសិទ្ធភាព និងគួរមានមុខងារដែលទាក់ទងនឹងការអនុវត្តកថាខ័ណ្ឌរង(ក) នេះ។ ចំណុចត្រួតពិនិត្យទាំងនេះគួរមានទំនាក់ទំនងទៅនឹងការប្រើប្រាស់ធនធានសេនេទិក ឬទៅនឹងការប្រមូលព័ត៌មានពាក់ព័ន្ធនៅក្នុងដំណាក់កាលណាមួយនៃការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការច្នៃប្រឌិតថ្មីៗ បុរេពាណិជ្ជកម្ម ឬពាណិជ្ជកម្ម ។

(ខ) លើកទឹកចិត្តអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ធនធានសេនេទិក ដើម្បីបញ្ចូលបទប្បញ្ញត្តិនានាទៅក្នុងលក្ខខណ្ឌព្រមព្រៀងរួម ដើម្បីចែករំលែកព័ត៌មាន អំពីការអនុវត្តលក្ខខណ្ឌទាំងនោះ រួមទាំងតាមរយៈលក្ខខណ្ឌក្នុងការរាយការណ៍ផង និង

(គ) លើកទឹកចិត្តឱ្យមានការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធទំនាក់ទំនងដែលមានតម្លៃសមរម្យ។

២. លិខិតអនុញ្ញាត ឬលិខិតដែលមានតម្លៃស្មើដែលបានចេញ អនុលោមតាមមាត្រា៦ កថាខ័ណ្ឌ៣ (ង) និងត្រូវបញ្ជូនទៅចំពោះការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងបែងចែកផលប្រយោជន៍ ត្រូវរួមចំណែកដល់លិខិតបញ្ជាក់ពីការគោរពតាមបទប្បញ្ញត្តិដែលទទួលស្គាល់ជាអន្តរជាតិ។

៣. លិខិតបញ្ជាក់ពីការគោរពតាមបទប្បញ្ញត្តិដែលទទួលស្គាល់ជាអន្តរជាតិ ត្រូវចាត់ទុកជាភស្តុតាង ដែលថាធនធានសេនេទិកដែលមានបញ្ជាក់ក្នុងលិខិតបញ្ជាក់នោះ ត្រូវប្រើប្រាស់យោងតាមការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន និងដែលថាលក្ខខណ្ឌព្រមព្រៀងរួមត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិ ឬលក្ខខណ្ឌស្តីពីការទទួល និងបែងចែកផលប្រយោជន៍ក្នុងប្រទេសរបស់ភាគីដែលផ្តល់ការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន។

៤. លិខិតបញ្ជាក់ពីការគោរពតាមបទប្បញ្ញត្តិដែលទទួលស្គាល់ជាអន្តរជាតិ ត្រូវមានព័ត៌មានអប្បបរមានៅពេលដែលវាមិនមែនជាព័ត៌មានសម្ងាត់ដូចជា៖

(ក) អាជ្ញាធរចេញលិខិតបញ្ជាក់

(ខ) កាលបរិច្ឆេទចេញលិខិតបញ្ជាក់

(គ) អ្នកផ្គត់ផ្គង់

(ឃ) ចំណុចកំណត់សម្គាល់ពិសេសនៃលិខិតបញ្ជាក់នោះ

(ង) បុគ្គល ឬអង្គភាពដែលខ្លួនបានចេញការព្រមព្រៀងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ជាមុន

(ច) កម្មវត្ថុ ឬធនធានសេនេទិកដែលបញ្ជាក់ក្នុងលិខិតបញ្ជាក់

(ឆ) ការបញ្ជាក់ថាមានការបង្កើតលក្ខខណ្ឌព្រមព្រៀងរួម

(ជ) ការបញ្ជាក់ថាមានការព្រមព្រៀងដោយផ្អែកលើព័ត៌មានជាមុន និង

(ឈ) ការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម និង/ឬមិនមែនពាណិជ្ជកម្ម

## មាត្រា ១៨
## ការគោរពតាមលក្ខខណ្ឌព្រមព្រៀងរួម

១. ក្នុងការអនុវត្តមាត្រា៦ កថាខ័ណ្ឌ៣ (ឆ) (ជ) និងមាត្រា៧ ភាគីនីមួយៗត្រូវលើកទឹកចិត្តដល់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ធនធានសេនេទិក និង/ឬចំណេះដឹងប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិកឱ្យបញ្ចូលបទប្បញ្ញត្តិ ទៅក្នុងលក្ខខណ្ឌព្រមព្រៀងរួម ដើម្បីដោះស្រាយវិវាទឱ្យបានសមស្រប ក្នុងនោះរួមទាំង ៖

(ក) ដែនសមត្ថកិច្ចដែលលក្ខខណ្ឌទាំងនេះនឹងដាក់ឱ្យនៅក្នុងដំណើរការដោះស្រាយវិវាទ

(ខ) ច្បាប់ជាធរមាន និង/ឬ

(គ) ជម្រើសសម្រាប់ដោះស្រាយវិវាទ មានដូចជា៖ ការផ្សះផ្សា ឬអាជ្ញាកណ្តាល

២. ភាគីនីមួយៗត្រូវធានាថា ឱកាសក្នុងការស្វះស្វែងរកជំនួយ គឺអាចមាននៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួនដែលស្រប នឹងលក្ខខណ្ឌយុត្តាធិការជាធរមាន ក្នុងករណីមានវិវាទពីលក្ខខណ្ឌព្រមព្រៀងរួម។

៣. ភាគីនីមួយៗត្រូវមានវិធានការដែលមានប្រសិទ្ធភាព សមស្របទាក់ទងនឹង ៖

(ក) ការស្វែងរកដំណោះស្រាយដោយយុត្តិធម៌ និង

(ខ) ការប្រើប្រាស់យន្តការទាក់ទងទៅនឹងការទទួលស្គាល់រួមគ្នា និងការអនុវត្តសាលក្រមបរទេស និង ការសម្រេចរបស់អាជ្ញាកណ្តាល

៤. ប្រសិទ្ធភាពនៃមាត្រានេះនឹងត្រូវពិនិត្យឡើងវិញដោយសន្និសីទភាគី ដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ ដោយអនុលោមតាមមាត្រា៣១ នៃពិធីសារនេះ ។

## មាត្រា ១៩
## ខសន្យាគំរូ

១. នៅពេលសមស្រប ភាគីនីមួយៗត្រូវជម្រុញឱ្យការអភិវឌ្ឍ បច្ចុប្បន្នភាព និងការប្រើប្រាស់ខសន្យាគំរូតាម វិស័យ និងអន្តរវិស័យសម្រាប់លក្ខខណ្ឌព្រមព្រៀងរួម។

២. សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវវាយតម្លៃជារួមក្នុងរយៈពេលទៀងទាត់ពីការប្រើប្រាស់ ខសន្យាគំរូតាមវិស័យ និងអន្តរវិស័យ ។

## មាត្រា ២០
## ក្រមប្រតិបត្តិ គោលការណ៍ណែនាំ និងការអនុវត្ត និង/ឬបទដ្ឋានល្អបំផុត

១. នៅពេលសមស្រប ភាគីនីមួយៗត្រូវជម្រុញឱ្យមានការអភិវឌ្ឍ ការធ្វើបច្ចុប្បន្នភាព និងការប្រើប្រាស់ក្រម ប្រតិបត្តិដោយស្ម័គ្រចិត្ត គោលការណ៍ណែនាំ និងការអនុវត្ត និង/ឬបទដ្ឋានដ៏ប្រសើរបំផុតទាក់ទងទៅនឹងការ ទទួល និងការបែងចែក ផលប្រយោជន៍។

២. សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវវាយតម្លៃជារួមក្នុងរយៈពេលទៀងទាត់លើក្រមប្រតិបត្តិដោយស្ម័គ្រចិត្ត គោលការណ៍ណែនាំ និងការអនុវត្ត និង/ឬបទដ្ឋានដ៏ប្រសើរបំផុត ព្រមទាំងពិចារណាលើការអនុម័តនូវក្រមប្រតិបត្តិ គោលការណ៍ណែនាំ និងការអនុវត្ត និង/ឬបទដ្ឋានជាក់លាក់។

## មាត្រា ២១
## ការលើកកម្ពស់ការយល់ដឹង

ភាគីនីមួយៗ ត្រូវចាត់វិធានការក្នុងការលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃធនធានសេនេទិក និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងធនធានសេនេទិក និងពីបញ្ហានានាស្តីពីការទទួល និងការបែងចែកផលប្រយោជន៍។ វិធានការទាំងនេះអាចរួមបញ្ចូលចំណុចផ្សេងៗដូចខាងក្រោម ៖

(ក) ផ្សព្វផ្សាយពិធីសារនេះ រួមទាំងគោលបំណងរបស់ពិធីសារ
(ខ) រៀបចំប្រជុំពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ
(គ) បង្កើត និងថែរក្សាការិយាល័យជំនួយមួយសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
(ឃ) ផ្សព្វផ្សាយព័ត៌មាន តាមរយៈការិយាល័យចែកចាយព័ត៌មានថ្នាក់ជាតិ
(ង) ផ្សព្វផ្សាយក្រមប្រតិបត្តិ គោលការណ៍ណែនាំ និងការអនុវត្ត និង/ឬបទដ្ឋានដែលល្អបំផុត ដោយពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
(ច) នៅពេលសមស្រប ផ្សព្វផ្សាយពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងប្រទេស តំបន់ និងអន្តរជាតិ
(ឆ) អប់រំ បណ្តុះបណ្តាលអ្នកប្រើប្រាស់ អ្នកផ្គត់ផ្គង់ធនធានសេនេទិក និងចំណេះដឹងប្រពៃណី ទាក់ទងនឹងធនធានសេនេទិកអំពីកាតព្វកិច្ចក្នុងការទទួល និងការបែងចែកផលប្រយោជន៍
(ជ) ការដាក់បញ្ចូលសហគមន៍ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តពិធីសារនេះ និង
(ឈ) ការលើកកម្ពស់ការយល់ដឹងអំពីពិធីសារ និងនីតិវិធីរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

## មាត្រា ២២
## សមត្ថភាព

១. ភាគីទាំងអស់ត្រូវសហការគ្នាក្នុងការកសាងសមត្ថភាព ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងធនធានមនុស្ស ព្រមទាំងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តពិធីសារនេះឱ្យមានប្រសិទ្ធភាពនៅក្នុងភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ជា ពិសេសប្រទេសដែលមានការអភិវឌ្ឍន៍តិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាល ក្នុងនោះរួមទាំងតាមរយៈស្ថាប័ន និងអង្គការថ្នាក់ជាតិ អនុតំបន់ តំបន់ និងពិភពលោក។ ក្នុងបរិបទនេះ ភាគីទាំងអស់ គួរសម្របសម្រួលការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានព្រមទាំងភាគីពាក់ព័ន្ធដោយរួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

២. តម្រូវការនៃភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែល មានការអភិវឌ្ឍតិចបំផុត ព្រមទាំងប្រទេសកំពុងអភិវឌ្ឍន៍នៅកោះតូចៗ និង ប្រទេសមានសេដ្ឋកិច្ចអន្តរកាលចំពោះធនធានហិរញ្ញវត្ថុ ដោយអនុលោម

តាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ ត្រូវយកចិត្តទុកដាក់ឱ្យបានពេញលេញលើការកសាង និងការអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តពិធីសានេះ។

៣. ដើម្បីបានជាមូលដ្ឋានសម្រាប់ចាត់វិធានការសមស្របក្នុងការអនុវត្តពិធីសារនេះ ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍ តិចតួចបំផុត ព្រមទាំងប្រទេសកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ និងប្រទេសមាន សេដ្ឋកិច្ចអន្តរកាល គួរកំណត់ពីតម្រូវការសមត្ថភាព និងផ្នែកជាអាទិភាពតាមរយៈស្វ័យវាយតម្លៃលើសមត្ថភាពថ្នាក់ជាតិ។ ដើម្បីធ្វើដូចនេះបាន ភាគីទាំងនោះគួរគាំទ្រដល់តម្រូវការសមត្ថភាព និងផ្នែកជា អាទិភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងភាគីពាក់ព័ន្ធតាមការកំណត់របស់សហគមន៍ទាំងនេះ ដោយសង្កត់ធ្ងន់ទៅលើតម្រូវការសមត្ថភាព និងផ្នែកជាអាទិភាពរបស់ស្ត្រី។

៤. ក្នុងការគាំទ្រដល់ការអនុវត្តពិធីសារនេះ ការកសាង និងការអភិវឌ្ឍសមត្ថភាពអាចលើកឡើងនូវចំណុចសំខាន់ៗ មួយចំនួនដូចខាងក្រោមៈ

(ក) សមត្ថភាពក្នុងការអនុវត្ត និងគោរពតាមកាតព្វកិច្ចនៃពិធីសារនេះ
(ខ) សមត្ថភាពក្នុងការចរចាលើលក្ខខណ្ឌព្រមព្រៀងរួម
(គ) សមត្ថភាពក្នុងការបង្កើត អនុវត្ត និងពង្រឹងវិធានការច្បាប់ រដ្ឋបាល ឬគោលនយោបាយស្តីពីការទទួល និងការបែងចែកផលប្រយោជន៍ និង
(ឃ) សមត្ថភាពរបស់ប្រទេសក្នុងការអភិវឌ្ឍលទ្ធភាពក្នុងការសិក្សាស្រាវជ្រាវពីប្រភពដើម ដើម្បីបន្ថែមតម្លៃទៅលើធនធានសេនេទិករបស់ខ្លួន។

៥. រាល់វិធានការដែលចែងក្នុងកថាខ័ណ្ឌ១ ដល់៤ ខាងលើ អាចបញ្ចូលនូវចំណុចដូចខាងក្រោម ៖

(ក) ការអភិវឌ្ឍស្ថាប័ន និងផ្នែកច្បាប់
(ខ) ការលើកកម្ពស់សមធម៌ និងស្មើភាពក្នុងការចរចា ដូចជាការបណ្តុះបណ្តាលក្នុងការចរចាលើលក្ខខណ្ឌព្រមព្រៀងរួម
(គ) ការត្រួតពិនិត្យ និងការអនុវត្តលើការព្រមព្រៀង
(ឃ) ដាក់ឱ្យអនុវត្តនូវឧបករណ៍ទំនាក់ទំនង និងប្រព័ន្ធអ៊ីនធឺណែត ដែលទំនើបបំផុតសម្រាប់សកម្មភាពទទួល និងបែងចែកផលប្រយោជន៍
(ង) ការបង្កើត និងប្រើប្រាស់នូវវិធីសាស្ត្រវាយតម្លៃ
(ច) ការស្វែងរកប្រភេទរុក្ខជាតិ និងសត្វ ការសិក្សាស្រាវជ្រាវពាក់ព័ន្ធ និងការសិក្សាស្រាវជ្រាវពីប្រភេទរុក្ខជាតិ និងសត្វ
(ឆ) ការផ្ទេរបច្ចេកវិទ្យា និងសមត្ថភាពបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធដើម្បីធ្វើឱ្យការផ្ទេរបច្ចេកវិទ្យាមាននិរន្តរភាព
(ជ) ពង្រឹងការរួមចំណែកនៃសកម្មភាពទទួល និងចែករំលែកផលប្រយោជន៍ដើម្បីអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ប្រកដោយនិរន្តរភាពនៃសមាសភាពរបស់វា
(ឈ) វិធានការពិសេសដើម្បីបង្កើនសមត្ថភាពរបស់ភាគីពាក់ព័ន្ធទាក់ទងនឹងការទទួល និងបែងចែកផលប្រយោជន៍ និង

(ញ) វិធានការពិសេសក្នុងការបង្កើនសមត្ថភាពនៃសហគមន៍ជនជាតិដើម និងសហគមន៍មូលដ្ឋានដោយសង្កត់ធ្ងន់លើការបង្កើនសមត្ថភាពស្ត្រីក្នុងសហគមន៍ទាំងនោះ ទាក់ទងនឹងការទទួលធនធានសេនេទិក និង/ឬ ចំណេះដឹងជាប្រពៃណីទាក់ទងនឹងធនធានសេនេទិក។

៦. ពត៌មានស្តីអំពីការផ្តើមគំនិតក្នុងការកសាង និងការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដោយត្រូវបានអនុវត្ត អនុលោមតាមកថាខ័ណ្ឌ១ ដល់៥ ខាងលើ គួរបញ្ជូនទៅដល់ការិយាល័យចែកចាយព័ត៌មានស្តីពីការទទួល និងចែករំលែកផលប្រយោជន៍ដើម្បីពង្រីកកម្លាំងរួម និងកិច្ចសម្របសម្រួលក្នុងការកសាង និងអភិវឌ្ឍសមត្ថភាពការទទួល និងបែងចែកផលប្រយោជន៍។

## មាត្រា ២៣
## ការផ្ទេរបច្ចេកវិទ្យា កិច្ចសហការ និងកិច្ចប្រតិបត្តិការ

អនុលោមតាមមាត្រា១៥ ១៦ ១៨ និង១៩ របស់អនុសញ្ញានេះ ភាគីទាំងអស់ ត្រូវសហការ និងរួបរួមគ្នាក្នុងកម្មវិធីសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកទេស និងវិទ្យាសាស្ត្រ ក្នុងនោះរួមទាំងសកម្មភាពសិក្សាស្រាវជ្រាវខាងជីវបច្ចេកវិទ្យា ដែលជាមធ្យោបាយមួយដើម្បីឈានទៅសម្រេចវត្ថុបំណងនៃពិធីសារនេះ។ ភាគីទាំងអស់ត្រូវមានសកម្មភាពក្នុងការផ្សព្វផ្សាយ និងជម្រុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យាទៅភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ព្រមទាំងបណ្តារដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ និងភាគីដែលមានសេដ្ឋកិច្ចអន្តរកាល ដើម្បីជួយសម្រួលដល់ការបង្កើត និងការពង្រឹងមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រឹមត្រូវ និងល្អៗដើម្បីឈានទៅសម្រេចវត្ថុបំណងនៃអនុសញ្ញា និងពិធីសារនេះ។ នៅពេលអាចធ្វើបាន និងសមស្រប សកម្មភាពសហប្រតិបត្តិការត្រូវអនុវត្តនៅក្នុង និងជាមួយភាគីមួយ ឬភាគីច្រើន ដែលផ្គត់ផ្គង់ ធនធានសេនេទិកដែលប្រទេសមួយ ឬប្រទេសជាច្រើនជាប្រភពនៃធនធានបែបនេះ ឬក៏ភាគីមួយ ឬច្រើនដែលត្រូវការធនធានសេនេទិក ដោយអនុលោមតាមអនុសញ្ញានេះ។

## មាត្រា ២៤
## ភាគីមិនចុះកិច្ចសន្យា

ភាគីទាំងអស់ ត្រូវជម្រុញភាគីមិនទាន់ចុះកិច្ចសន្យាឱ្យគោរពតាមពិធីសារនេះ និងចូលរួមផ្តល់ព័ត៌មានសមស្របដល់ការិយាល័យចែកចាយព័ត៌មានស្តីពី ការទទួល និងបែងចែកផលប្រយោជន៍។

## មាត្រា ២៥
## យន្តការ និងធនធានហិរញ្ញវត្ថុ

១. នៅពេលពិចារណាពីធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តពិធីសារនេះ ភាគីទាំងអស់ត្រូវពិនិត្យលើបទប្បញ្ញត្តិក្នុងមាត្រា២០ នៃអនុសញ្ញានេះ។

២. យន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះត្រូវតែ ជាយន្តការហិរញ្ញវត្ថុសម្រាប់ពិធីសារនេះ។

៣. ទាក់ទងនឹងការកសាង និងអភិវឌ្ឍសមត្ថភាពដែលមានចែងក្នុងមាត្រា២២នៃពិធីសារនេះ សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ក្នុងការផ្តល់ការណែនាំអំពីយន្តការហិរញ្ញវត្ថុដោយយោងទៅលើ កថាខ័ណ្ឌ២ ខាង

លើ សម្រាប់ឱ្យសន្និសីទភាគីទាំងអស់ធ្វើការពិចារណានោះ ត្រូវយកចិត្តទុកដាក់លើតម្រូវការធនធានហិរញ្ញវត្ថុរបស់ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ព្រមទាំង ប្រទេសកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ និងភាគីមានសេដ្ឋកិច្ចអន្តរកាល ព្រមទាំងតម្រូវការសមត្ថភាព និងផ្នែកជាអាទិភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន រួមទាំងស្ត្រីនៅក្នុងសហគមន៍ទាំងនេះ។

៤. ក្នុងបរិបទនៃកថាខ័ណ្ឌ១ខាងលើភាគីទាំងអស់ក៏ត្រូវយកចិត្តទុកដាក់លើតម្រូវការរបស់ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ព្រមទាំងប្រទេសកំពុងអភិវឌ្ឍន៍នៅតាម កោះតូចៗ និងភាគីដែលមានសេដ្ឋកិច្ចអន្តរកាលដើម្បីកំណត់ និងអនុវត្តតម្រូវការនៃការកសាង និងអភិវឌ្ឍសមត្ថភាពរបស់ប្រទេសទាំងនោះដើម្បីអនុវត្តពិធីសារនេះ។

៥. ការណែនាំអំពីយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងសន្និសីទភាគី ក្នុងនោះរួមទាំងសេចក្តីសម្រេចដែលការអនុម័តពិធីសារនេះ ត្រូវអនុវត្តដូចគ្នានឹងបទប្បញ្ញត្តិនានានៃពិធីសារនេះ។

៦. ភាគីដែលជាប្រទេសអភិវឌ្ឍន៍ក៏អាចផ្តល់ធនធានហិរញ្ញវត្ថុ និងធនធានផ្សេងៗ ហើយភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចអន្តរកាលត្រូវត្រៀមខ្លួនការប្រើប្រាស់ធនធានទាំងនេះ សម្រាប់អនុវត្តបទប្បញ្ញត្តិនានានៃពិធីសារនេះ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី តំបន់ និងពហុភាគី។

## មាត្រា ២៦
## សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីទាំងអស់របស់ពិធីសារ

១. សន្និសីទរបស់ភាគី ត្រូវតែជាកិច្ចប្រជុំភាគីនៃពិធីសារនេះ។

២. ភាគីទាំងអស់ដែលមិនមែនជាភាគីនៃពិធីសារនេះ អាចចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍លើដំណើរការនៃកិច្ចប្រជុំណាមួយនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំភាគីនៃពិធីសារ។ ដោយសារសន្និសីទភាគីជាកិច្ចប្រជុំភាគីនៃពិធីសារ សេចក្តីសម្រេចនៅក្រោមពិធីសារ ត្រូវធ្វើឡើងដោយភាគីនៃពិធីសារនេះប៉ុណ្ណោះ។

៣. ដោយសារសន្និសីទនេះជាកិច្ចប្រជុំភាគីនៃពិធីសារ សមាជិកណាម្នាក់នៃការិយាល័យសិន្និសីទនៃភាគីដែលតំណាងឱ្យភាគីមួយនៃអនុសញ្ញា ប៉ុន្តែក្នុងពេលនោះមិនមែនជាភាគីនៃពិធីសារនេះ ត្រូវបានជំនួសដោយសមាជិកណាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសពីក្នុងចំណោមភាគីនៃពិធីសារ។

៤. សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់លើការអនុវត្តពិធីសារនេះ ហើយត្រូវធ្វើសេចក្តីសម្រេចដែលចាំបាច់ ដើម្បីជម្រុញការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ សន្និសីទភាគីត្រូវអនុវត្តតួនាទីដែលផ្តល់ដោយពិធីសារនេះ និងត្រូវ ៖

(ក) ផ្តល់អនុសាសន៍ទៅលើបញ្ហាដែលចាំបាច់ដើម្បីអនុវត្តពិធីសារ
(ខ) បង្កើតអនុគណៈកម្មាធិការដែលចាំបាច់ដើម្បីអនុវត្តពិធីសារ
(គ) នៅពេលសមស្រប ស្វែងរក និងប្រើប្រាស់សេវានានាព្រមទាំងសហប្រតិបត្តិការ និងព័ត៌មានដែលបានផ្តល់ពីអង្គការអន្តរជាតិ ស្ថាប័នអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានសមត្ថកិច្ច

(ឃ) បង្កើតទម្រង់ និងរយៈពេលសម្រាប់ផ្សព្វផ្សាយព័ត៌មានដែលត្រូវ ផ្ដល់ឱ្យអនុលោមតាមមាត្រា២៩ នៃពិធីសារ ហើយយកចិត្តទុកដាក់លើព័ត៌មាន និងរបាយការណ៍ដែលអនុគណៈកម្មាធិការបានដាក់ជូន

(ង) នៅពេលចាំបាច់ ពិចារណា អនុម័តវិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វា ព្រមទាំងឧបសម្ព័ន្ធបន្ថែមនៃពិធីសារនេះដែលចាំបាច់សម្រាប់អនុវត្ត និង

(ច) អនុវត្តមុខងារផ្សេងៗដែលចាំបាច់ដើម្បីអនុវត្តពិធីសារ

៥. វិធានស្ដីពីនីតិវិធីសម្រាប់សន្និសីទភាគី និងវិធានហិរញ្ញវត្ថុរបស់អនុសញ្ញានេះ ត្រូវអនុវត្តស្របគ្នា នៅក្រោមពិធីសារនេះ លើកលែងតែមានសេចក្ដីសម្រេចជាឯកច្ឆ័ន្ទដោយសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ។

៦. កិច្ចប្រជុំលើកដំបូងនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវបានកោះប្រជុំដោយលេខាធិការដ្ឋាន និងត្រូវធ្វើឡើងស្របគ្នាជាមួយនឹងកិច្ចប្រជុំលើកទី១ នៃសន្និសីទរបស់ភាគីទាំងអស់ដែលគ្រោងនឹងធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារ។ កិច្ចប្រជុំសាមញ្ញបន្តបន្ទាប់មកទៀតនៃសន្និសីទ ភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវបានប្រារព្ធធ្វើឡើងស្របគ្នាជាមួយនឹងកិច្ចប្រជុំសាមញ្ញនៃសន្និសីទភាគី លើកលែងតែមានការសម្រេចផ្សេងដោយសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ។

៧. កិច្ចប្រជុំវិសាមញ្ញនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវធ្វើឡើងនៅពេលផ្សេងទៀត នៅពេលសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារគិតថាចាំបាច់ ឬនៅពេលដែលមានសំណើ ជាលាយល័ក្ខណ៍អក្សរពីភាគីណាមួយ ឱ្យតែសំណើនេះមានសំឡេងគាំទ្រយ៉ាងតិច១ភាគ៣ នៃភាគីទាំងអស់ បន្ទាប់ពីសំណើនេះត្រូវបានផ្ញើទៅភាគីទាំងនោះដោយលេខាធិការដ្ឋានក្នុងរយៈពេលប្រាំមួយខែ។

៨. អង្គការសហប្រជាជាតិ ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ ទីភ្នាក់ងារថាមពលអាតូមិក អន្តរជាតិ ព្រមទាំងរដ្ឋជាសមាជិក និងអ្នកសង្កេតការណ៍ដែលមិនមែនជាភាគីនៃអនុសញ្ញា អាចធ្វើជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំសន្និសីទភាគីនៃពិធីសារនេះ។ ស្ថាប័ន ឬទីភ្នាក់ងារណាមួយ ទោះបីជាស្ថាប័នជាតិ ឬអន្តរជាតិ ស្ថាប័នរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានចំណេះដឹងក្នុងបញ្ហាទាំងឡាយដែលបានកំណត់ក្នុងពិធីសារ ហើយដែលបានជូនដំណឹងទៅដល់លេខាធិការដ្ឋានអំពីបំណងចង់ចូលរួមនៅក្នុងកិច្ចប្រជុំ នៃសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ។ ក្នុងនាមជាអ្នកសង្កេតការណ៍អាចត្រូវបានអនុញ្ញាត លើកលែងតែការជំទាស់ពីសមាជិកយ៉ាងហោចណាស់មួយភាគបីនៃភាគីដែលចូលរួមក្នុងសន្និសីទ។ លើកលែងតែមានការចែងផ្សេងនៅក្នុងមាត្រានេះ ការអនុញ្ញាត និងការចូលរួមរបស់ក្រុមអ្នកសង្កេតការណ៍ ត្រូវផ្អែកលើវិធានស្ដីពីនីតិវិធី ដូចមានចែងក្នុងកថាខណ្ឌ៥ខាងលើ។

## មាត្រា ២៧
## អនុគណៈកម្មាធិការ

១. អនុគណៈកម្មាធិការដែលត្រូវបានបង្កើតឡើងក្រោមអនុសញ្ញា អាចប្រើប្រាស់ពិធីសារនេះ បន្ទាប់ពីមានសេចក្ដីសម្រេចនៃសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ។ សេចក្ដីសម្រេចចិត្តដូចនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ពី មុខងារភារកិច្ចដែលអនុគណៈកម្មាធិការនោះត្រូវអនុវត្ត។

២. ភាគីនៃអនុសញ្ញាដែលមិនមែនជាភាគីចុះហត្ថលេខានៃពិធីសារ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការ។ នៅពេលដែលអនុគណៈកម្មាធិការ នៃអនុសញ្ញាបំពេញការងារជាអនុគណៈកម្មាធិការនៃពិធីសារ សេចក្តីសម្រេចនានានៅក្រោមពិធីសារនេះ ត្រូវធ្វើឡើងដោយភាគីនៃពិធីសារប៉ុណ្ណោះ។

៣. នៅពេលអនុគណៈកម្មាធិការនៃអនុសញ្ញា បំពេញតួនាទីរបស់ខ្លួនពាក់ព័ន្ធទៅនឹងចំណុចផ្សេងៗក្នុងពិធីសារ សមាជិកណាមួយនៃការិយាល័យរបស់អនុគណៈកម្មាធិការនោះ ដែលតំណាងឱ្យភាគីនៃអនុសញ្ញា ប៉ុន្តែមិនមែនជាភាគីនៃពិធីសារ ត្រូវបានជំនួសដោយសមាជិកមួយរូបដែលនឹងត្រូវបានជ្រើសចេញពីចំណោមភាគីនៃពិធីសារនេះ។

## មាត្រា ២៨
## លេខាធិការដ្ឋាន

១. លេខាធិការដ្ឋានដែលបានបង្កើតឡើងដោយមាត្រា២៤ នៃអនុសញ្ញាត្រូវមានតួនាទីជាលេខាធិការដ្ឋាននៃពិធីសារ។

២. មាត្រា២៤ កថាខ័ណ្ឌ១ នៃអនុសញ្ញាស្តីពីតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះត្រូវអនុវត្តស្របគ្នានៅក្រោមពិធីសារ។

៣. ក្នុងកម្រិតមួយដែលមានការបញ្ជាក់ពីការចំណាយច្បាស់លាស់ ការចំណាយសម្រាប់សេវារបស់អគ្គលេខាធិការនៃពិធីសារ ត្រូវបានបំពេញដោយភាគីទាំងអស់។ នៅឯកិច្ចប្រជុំលើកដំបូងនៃសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះត្រូវសម្រេចលើគម្រោងថវិកាសំខាន់សម្រាប់បម្រើគោលបំណង។

## មាត្រា ២៩
## ការត្រួតពិនិត្យ និងការរាយការណ៍

ភាគីនីមួយៗ ត្រូវត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមពិធីសារ ហើយត្រូវរាយការណ៍ទៅសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារអំពីវិធានការដែលបានធ្វើឡើងដើម្បីអនុវត្តពិធីសារ ដោយផ្អែកតាមពេលវេលាកំណត់ និងទម្រង់របាយការណ៍ដែលបានកំណត់ដោយសន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ។

## មាត្រា ៣០
## នីតិវិធី និងយន្តការក្នុងការលើកកម្ពស់ការអនុវត្តតាមពិធីសារ

នៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន សន្និសីទភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារ ត្រូវគិតពិចារណា និងអនុម័តលើនីតិវិធីសហប្រតិបត្តិការ និងយន្តការស្ថាប័នក្នុងការលើកកម្ពស់ការអនុវត្តតាមបទប្បញ្ញត្តិនានា នៃពិធីសារ និងដោះស្រាយករណីដែលមិនគោរពតាមពិធីសារ។ នីតិវិធី និងយន្តការទាំងនេះត្រូវដាក់បញ្ចូលទាំងបទប្បញ្ញត្តិទាំងឡាយណាក្នុងការផ្តល់យោបល់ ឬជំនួយនៅពេលសមស្រប។ នីតិវិធី និងយន្តការទាំងនេះ មិនត្រូវ

បំបែកចេញ និងមិនប៉ះពាល់ដល់នីតិវិធី និងយន្តការក្នុងការដោះស្រាយវិវាទ ដែលមានចែងនៅក្នុងមាត្រា២៧ នៃអនុសញ្ញា។

## មាត្រា ៣១
## ការវាយតម្លៃ និងការត្រួតពិនិត្យឡើងវិញ

សន្និសីទភាគីដែលជាកិច្ចប្រជុំភាគី នៃពិធីសារនេះត្រូវធ្វើការវាយតម្លៃទៅលើប្រសិទ្ធភាពនៃពិធីសារនេះ ក្នុងរយៈពេល៤ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃពិធីសារនេះ និងទៅតាមពេលវេលាដែលបានកំណត់ដោយសន្និសីទ ភាគីដែលជាកិច្ចប្រជុំភាគីនៃពិធីសារនេះ ។

## មាត្រ ៣២
## ការចុះហត្ថលេខា

ពិធីសារនេះនឹងត្រូវដាក់ឱ្យចុះហត្ថលេខាដោយភាគីនៃអនុសញ្ញា នៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ ក្នុងទីក្រុង New York ចាប់ពីថ្ងៃទី 0២ ខែកុម្ភៈ ឆ្នាំ២០១១ ដល់ថ្ងៃទី0១ ខែកុម្ភៈ ឆ្នាំ២០១២។

## មាត្រា ៣៣
## ការចូលជាធរមាន

១. ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៩០ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តម្កល់ទុកសំណុំឯកសារទី៥០ ស្តីពីការផ្តល់សច្ចាប័ន ការព្រមទទួលយកការឯកភាព ឬការចូលជាសមាជិកដោយប្រទេស ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលជាភាគីនៃអនុសញ្ញា។

២. ពិធីសារនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលផ្តល់សច្ចាប័ន ព្រម ទទួលយក ឬឯកភាពលើពិធីសារ ឬចូលជាសមាជិកបន្ទាប់ពីការតម្កល់ទុកសំណុំឯកសារទី៥០ ដូចដែលបានចែងក្នុងកថាខ័ណ្ឌ១ខាងលើ នៅថ្ងៃទី៩០ បន្ទាប់ពីនៅថ្ងៃដែលប្រទេស ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះ តម្កល់ទុកសំណុំឯកសារស្តីពីការផ្តល់សច្ចាប័ន ការព្រមទទួលយកការឯកភាព ឬការចូលជាសមាជិករបស់ខ្លួន ឬនៅថ្ងៃដែលអនុសញ្ញាចូលជាធរមាននៅក្នុងរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់។

៣. ចំពោះគោលបំណងនៃកថាខ័ណ្ឌ១ និង២ ខាងលើ សំណុំឯកសារដែលបានតម្កល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ មិនត្រូវបានរាប់បញ្ចូលជាឯកសារបន្ថែមលើសំណុំឯកសារដែលបានដាក់តម្កល់ដោយប្រទេសដែលជាសមាជិកនៃអង្គការនេះ។

## មាត្រា ៣៤
## ការលើកលែង

ពុំមានករណីលើកលែងសម្រាប់ពិធីសារនេះទេ។

## មាត្រា ៣៥
## ការដកខ្លួនពីសមាជិកភាព

១. នៅពេលណាក៏ដោយបន្ទាប់ពីរយៈពេល២ឆ្នាំ នៃការចូលជាធរមាននៃពិធីសារភាគីដែលជាសមាជិកអាចដកខ្លួនចេញពីពិធីសារនេះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទទួលចុះបញ្ជី។

២. ការដកខ្លួនពីសមាជិកភាពត្រូវធ្វើឡើង នៅពេលផុតកំណត់រយៈពេល១ឆ្នាំ បន្ទាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងរបស់អ្នកទទួលចុះបញ្ជី ឬនៅថ្ងៃក្រោយដែលមានការកំណត់ នៅក្នុងសេចក្តីជូនដំណឹងក្នុងការដកខ្លួនពីសមាជិកភាព។

## មាត្រា ៣៦
## ច្បាប់ដើមនៃពិធីសារ

ច្បាប់ដើមនៃពិធីសារនេះដែលសរសេរជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្សី និងអេស្ប៉ាញ និងមានតម្លៃ ស្មើគ្នា ហើយត្រូវបានដាក់តម្កល់នៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ។

ដើម្បីជាសក្ខីភាព តំណាងរដ្ឋដូចខាងក្រោមដែលទទួលសិទ្ធិពេញច្បាប់ពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើពិធីសារ តាមកាលបរិច្ឆេទដែលបានកំណត់។

ធ្វើនៅណាហ្គូយ៉ា ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០

# ឧបសម្ព័ន្ធ
# ផលប្រយោជន៍ជាប្រាក់ និងមិនមែនជាប្រាក់

១. ផលប្រយោជន៍ជាប្រាក់អាចមាន ប៉ុន្តែមិនកំណត់ត្រឹមតែ ៖

(ក) តម្លៃទទួលសម្រាប់សំណាកនីមួយៗដែលបានប្រមូលឬបានទទួល

(ខ) ការចំណាយទុកមុន

(គ) ការចំណាយជាដំណាក់កាលសំខាន់ៗ

(ឃ) ការចំណាយលើការបង់ពន្ធ

(ង) តម្លៃអាជ្ញាប័ណ្ណក្នុងករណីការធ្វើអាជីវកម្ម

(ច) តម្លៃពិសេសដែលត្រូវចំណាយទៅលើមូលនិធិពិសេស ដើម្បីគាំទ្រលើការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃជីវៈចម្រុះ

(ឆ) ប្រាក់បៀវត្ស និងលក្ខខណ្ឌពិសេសដែលបានឯកភាពរួម

(ជ) ការផ្តល់មូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ

(ឈ) ការធ្វើអាជីវកម្មរួមគ្នា

(ញ) ភាពជាម្ចាស់រួមគ្នានៃកម្មសិទ្ធិបញ្ញាពាក់ព័ន្ធ

២. ផលប្រយោជន៍ដែលមិនមែនជាប្រាក់អាចមាន ប៉ុន្តែមិនកំណត់ត្រឹមតែ ៖

(ក) បែងចែកនៃលទ្ធផលការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ

(ខ) កិច្ចសហការ សហប្រតិបត្តិការ ការរួមចំណែកក្នុងកម្មវិធីអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ជាពិសេសសកម្មភាពសិក្សាស្រាវជ្រាវផ្នែកជីវបច្ចេកវិទ្យា បើអាចធ្វើបាន ជាមួយភាគីដែលផ្គត់ផ្គង់ធនធានសេនេទិក។

(គ) ការចូលរួមក្នុងការអភិវឌ្ឍផលិតផល

(ឃ) កិច្ចសហការ កិច្ចសហប្រតិបត្តិការ និងការរួមចំណែកក្នុងការអប់រំ និងបណ្តុះបណ្តាល

(ង) ការអនុញ្ញាតឱ្យចូលទៅក្នុងទីតាំងក្រៅតំបន់នៃធនធានសេនេទិក និងមូលដ្ឋានទិន្នន័យ

(ច) ការផ្ទេរទៅឱ្យអ្នកផ្គត់ផ្គង់ធនធានសេនេទិកនូវចំណេះដឹង និងបច្ចេកវិទ្យានៅក្រោមលក្ខខណ្ឌស្មើភាព និងមានអំណោយផលបំផុត ក្នុងនោះរួមទាំងលក្ខខណ្ឌសម្បទាន ពិសេសតាមការឯកភាពគ្នា ចំណេះដឹង និងបច្ចេកវិទ្យាដែលមានប្រយោជ៍ដល់ធនធានសេនេទិក ដែលមានដូចជាជីវបច្ចេកវិទ្យា ឬចំណេះដឹង និងបច្ចេកវិទ្យាដែលទាក់ទងទៅនឹងការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃជីវៈចម្រុះ

(ឆ) ការពង្រឹងសមត្ថភាពសម្រាប់ការផ្ទេរបច្ចេកវិទ្យា

(ជ) ការកសាងសមត្ថភាពស្ថាប័ន

(ឈ) ធនធានមនុស្ស និងសំភារៈដើម្បីពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រង និងការអនុវត្តនៃបទប្បញ្ញត្តិស្តីពីការទទួលធនធាន

(ញ) ការបណ្តុះបណ្តាលទាក់ទងនឹងធនធានសេនេទិក ដែលមានការចូលរួមយ៉ាងពេញលេញរបស់បណ្តាប្រទេសផ្គត់ផ្គង់ធនធានសេនេទិក និងប្រសិនបើអាចផ្តល់ការបណ្តុះបណ្តាលនៅក្នុងប្រទេសទាំងនោះ

(ដ) ការទទួលបានពត៌មានវិទ្យាសាស្រ្តទាក់ទងនឹងការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានជីវៈចម្រុះ រួមទាំងការធ្វើបញ្ជីជីវៈចម្រុះ និងការសិក្សាស្រាវជ្រាវអំពីប្រភេទសត្វ និងរុក្ខជាតិ

(ឋ) ការរួមចំណែកដល់សេដ្ឋកិច្ចក្នុងប្រទេស

(ឌ) ការសិក្សាស្រាវជ្រាវសម្រាប់បំពេញតម្រូវការអាទិភាព ដូចជា សុខភាព និងសុវត្ថិភាពអាហារ ការយកចិត្តទុកដាក់លើការប្រើប្រាស់ក្នុងប្រទេសនូវធនធានសេនេទិក ក្នុងភាគីដែលផ្តត់ផ្គង់ធនធានសេនេទិក

(ឍ) ទំនាក់ទំនងស្ថាប័ន និងវិជ្ជាជីវៈដែលអាចកើតមានពីកិច្ចព្រមព្រៀង អំពីការទទួល និងការបែងចែកផលប្រយោជន៍ និងសកម្មភាពសហប្រតិបត្តិការផ្សេងៗទៀត

(ណ) ផលប្រយោជន៍ទាក់ទងនឹងជីវភាពរស់នៅ និងអាហារ

(ត) ការទទួលស្គាល់ពីសង្គម

(ថ) ភាពជាម្ចាស់រួមគ្នានៃសិទ្ធិស្តីពីកម្មសិទ្ធបញ្ញា ដែលពាក់ព័ន្ធនឹងធនធានសេនេទិក